# អរិយធម៌សុងហៃ (Songhai civilizaiton)

អរិយធម៌ ឬ អាណាចក្រ សុងហៃ (Songhai) គឺជាអាណាចក្រមួយដែលសំខាន់ខាងផ្នែកពាណិជ្ជកម្មនៅក្នុងតំបន់អាហ្វ្រិចខាងលិច ហើយបច្ចុប្បន្នជាប្រទេសម៉ាលី (Mali)។ អរិយធម៌នេះចាប់ផ្តើមរីកចម្រើនខ្លាំង និងក្លាយជាអាណាចក្រដ៏ធំនៅក្នុងតំបន់នៅអំឡុងពេលស្តេច Sonni Ali គ្រប់គ្រងនៅស.វ.ទី ១៥។[១] ទឹកដីនៃអរិយធម៌នេះស្ទើទាំងស្រុងគឺជាទឹកដីនៃអាណាចក្រហ្គាវ (Gao) ដែលត្រូវបានអាណាចក្រសុងហៃវាយរលំ និងគ្រប់គ្រងនៅដើមស.វ.ទី ១៥[២] (រូបលេខ១)។ បន្ទាប់ពីគ្រប់គ្រងលើអាណាចក្រហ្គាវហើយ អាណាចក្រសុងហៃបានតាំងរាជធានីនៅតំបន់ ហ្គាវនោះ ហើយបានបង្កើតជាទីក្រុងមជ្ឈមណ្ឌលដ៏សំខាន់នៅក្នុងអាហ្វ្រិចខាងលិច។[៣] ទីក្រុងសំខាន់ៗនៅក្នុងអរិយធម៌ ឬអាណាចក្រនេះរួមមាន ទីក្រុង ឌីជេន (Djenné) ទីមបូកទូ (Timbuktu) និងទីក្រុងហ្គាវ (Gao) (រូបលេខ២-៤)។

ឌីជេន (Djenné) គឺជាក្រុងបុរាណស្ថិតនៅប្រមាណជាង១៣០គីឡូ ពីទីក្រុង Mopti និងមានចម្ងាយជាង៥០០គីឡូពីរាជធានី Bamako នៃប្រទេសម៉ាលី។ ទីក្រុងនេះកសាងឡើងនៅស.វ.ទី១១ និងនៅស.វ.ទី១៥ គ្រប់គ្រងដោយអាណាចក្រសុងហៃ។[៤] តាមរយៈការធ្វើកំណាយស្រាវជ្រាវនៅទីនេះចាប់ពីឆ្នាំ១៩៧៧ រហូតដល់១៩៩៧ បានបង្ហាញថានៅទីនេះមានមនុស្សមកតាំងទីរស់នៅប្រមាណជាងស.វ.ទី៣មុនគ.ស. ដោយបានរកឃើញវត្ថុសិល្បៈផ្សេងៗជាច្រើនទៀត។[៥]

ចំណែកឯទីក្រុងទីមបូកទូ (Timbuktu) ត្រូវបាគេដឹងថាជាទីក្រុងសាសនាអ៊ីស្លាមដ៏សំខាន់នៅក្នុងតំបន់អាហ្វ្រិចខាងលិច ។ ទីក្រុងនេះមានទីតាំងចម្ងាយប្រមាណ១៣គីឡូពី

[១] https://www.metmuseum.org/toah/hd/sghi/hd_sghi.htm

[២] ibid

[៣] https://www.britannica.com/place/Gao-Mali

[៤] ibid

[៥] https://whc.unesco.org/en/list/116

អត្ថបទដោយ៖ អេង តុលា

ទន្ទេនីហ្សេ ហើយត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ១៩៨៨។ នៅទីនេះឃើញមានសំណង់ព្រះវិហារអ៊ីស្លាមដ៏ធំមួយដែលហៅថា Great Mosque កសាងនៅស.វ.ទី១៤។ គួរបញ្ជាក់ដែរថា អរិយធម៌សុងហៃនេះគឺគោរពប្រតិបត្តិសាសនាអ៊ីស្លាម ។

រីឯទីក្រុង ហ្គៅ វិញ មានទីតាំងស្ថិតនៅក្បែរនឹងទន្ទេនីហ្សេ នៅខាងកើតនៃប្រទេសម៉ាលី និងជាកន្លែងជួញដូរនៅក្នុងតំបន់សាហារ៉ា (Saharan)។ ជាពិសេសការជួញដូរ មាស ទុងដែង និងវត្ថុមានតំបន់ផ្សេងៗទៀតជាដើម។ នៅទីក្រុងនេះឃើញមានសំណង់ដីខ្ពស់មួយដែលហៅថា ជាផ្នូរស្តេច Askia (The Tomb of Askia)។ Askia muhammad គឺជាស្តេចដ៏មានកេរ្តិ៍ឈ្មោះល្បីល្បាញ និងមានឥទ្ធិពលម្នាក់នៅក្នុងអរិយធម៌សុងហៃ និងនៅក្នុងតំបន់អាហ្វ្រិចខាងលិច។[៦] សំណង់នេះត្រូវបានកសាងនៅស.វ.ទី១៥ ដែលជាសិល្បៈដែលបង្ហាញពីទម្រង់នៃអរិយធម៌របស់សុងហៃ។ ការកសាងសំណង់នេះ គឺធ្វើអំពីដីខ្ពស់ទៅលើ ដោយបង្កប់ជន្ទួញឈើនៅជុំវិញសំណង់ដីនោះ។

មនុស្សក្នុងអរិយធម៌នេះមានជំនាញក្នុងការផលិតវត្ថុសិល្បៈ តាមទម្រង់ប្លែកៗតែមានបច្ចេកទេសខ្ពស់ ដែលភាគច្រើនប្រើប្រាស់បច្ចេកទេសស្មូនដី ទៅជារូបអ្វីមួយរួចដុតឱ្យឆ្អិន និងជាពិសេសសំណង់ស្ថាបត្យកម្មនៅតាមទីក្រុងសំខាន់ដូចដែលបានបង្ហាញនៅខាងលើ (រូបលេខ៥-៦)។

អរិយធម៌ ឬអាណាចក្រសុងហៃត្រូវបានដួលរលំនៅស.វ.ទី ចុងស.វ.ទី១៦ បន្ទាប់ពីស្តេច Mohammad IV បានសុគត និងមានការឈ្លានពានពីសំណាកអរិយធម៌ដទៃទៀតជាពិសេ អាណាចក្រម៉ារ៉ុក។ សរុបមកអរិយធម៌នេះរីកចម្រើនខ្លាំងបានតែជាង១ស.វ.ប៉ុន្តែបានបង្ហាញយ៉ាងច្រើន តាមរយៈសំណង់ស្ថាបត្យកម្ម វត្ថុសិល្បៈ និងវិសាលភាពទឹកដីធំធេង និងបង្ហាញអំពីបច្ចេកទេសយ៉ាងល្អក្នុងការកសាងសំណង់ទាំងនោះ។

[៦] https://www.oxfordreference.com/view/10.1093/oi/authority.20110803095428851

អត្ថបទដោយ៖ អេង តុលា




រូបលេខ១៖ ផែនទីនៃអរិយធម៌សុងហៃ

ប្រភព៖ www.worldhistory.com

អរិយធម៌ខ្មែរ
KHMER CIVILIZATION



រូបលេខ២៖ សំណង់ស្ថាបត្យកម្មនៅក្នុងទីក្រុង djenné

ប្រភព៖ www.unesco.org



រូបលេខ៣៖ ព្រះវិហារGreat of Mosque នៅក្នុងទីក្រុង ទីមបូកទូ (Timbuktu)

ប្រភព៖ www.unesco.org

អត្ថបទដោយ៖ អេង តុលា



រូបលេខ៤៖ ផ្នូរស្តេច Askia (The Tomb of Askia)

ប្រភព៖ www.unesco.org





រូបលេខ ៥-៦៖ វត្ថុសិល្បៈក្នុងអរិយធម៌សុងហៃ

ប្រភព៖ www.metmuseum.rog

អត្ថបទដោយ៖ អេង តុលា

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា